**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៧០ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតតំបន់ការពារទេសភាពបឹងយ៉ាកអោម យ៉ាកកាវ៉

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើតតំបន់ការពារទេសភាពបឹងយ៉ាកអោម យ៉ាកកាវ៉ ដែលមានផ្ទៃដីទំហំ ១៣២,៥០ (មួយរយសាមសិបពីរហិចតានិងហាសិបអា) ស្ថិតក្នុងភូមិសាស្ត្រ ឃុំសេដា ស្រុកលំផាត់ ខេត្តរតនគិរី ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងមាននិយាមកា( UTM WGS 1984 Zone 48 N) ដូចខាងក្រោម៖

| ID | X | Y |
|---|---|---|
| 1 | 730779 | 1499059 |
| 2 | 730753 | 1499160 |
| 3 | 730796 | 1499197 |
| 4 | 730731 | 1499354 |
| 5 | 730553 | 1499272 |
| 6 | 730532 | 1499343 |
| 7 | 730402 | 1499375 |
| 8 | 730422 | 1499461 |
| 9 | 730486 | 1499433 |
| 10 | 730462 | 1499501 |
| 11 | 730420 | 1499768 |
| 12 | 730509 | 1499879 |
| 13 | 730591 | 1499862 |
| 14 | 730688 | 1499763 |

| ID | X | Y |
|---|---|---|
| 15 | 730808 | 1499856 |
| 16 | 730912 | 1499859 |
| 17 | 730980 | 1500021 |
| 18 | 730846 | 1498981 |
| 19 | 730767 | 1498921 |
| 20 | 730765 | 1498717 |
| 21 | 730772 | 1498533 |
| 22 | 730645 | 1498504 |
| 23 | 730524 | 1498448 |
| 24 | 730708 | 1498338 |
| 25 | 730723 | 1498412 |
| 26 | 730877 | 1498465 |
| 27 | 730985 | 1498515 |
| 28 | 731120 | 1498596 |

| ID | X | Y |
|---|---|---|
| 29 | 731251 | 1498613 |
| 30 | 731357 | 1498727 |
| 31 | 731436 | 1498844 |
| 32 | 731516 | 1498933 |
| 33 | 731638 | 1498903 |
| 34 | 731694 | 1498974 |
| 35 | 731645 | 1499071 |
| 36 | 731728 | 1499259 |
| 37 | 731779 | 1499407 |
| 38 | 731592 | 1499622 |
| 39 | 731459 | 1499928 |
| 40 | 731126 | 1500032 |

**មាត្រា២ ._**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ធានាការថែរក្សានិងការពារសោភ័ណភាពធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី សារព័នមជ្ឈដ្ឋានធម្មជាតិ សត្វព្រៃ រុក្ខជាតិ និងវប្បធម៌
- ថែរក្សាការពារលំនឹងបរិស្ថាននិងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ
- ផ្តល់ផលិតផលនិងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋានក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះនិងធនធានធម្មជាតិក្នុងតំបន់
- ថែរក្សាការពារ វប្បធម៌ ប្រពៃណី ការអភិវឌ្ឍ និងសារៈសំខាន់ផ្នែកវប្បធម៌របស់សហគមន៍មូលដ្ឋាន
- បង្កើនតួនាទីប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ការពារធម្មជាតិ សម្រាប់ជាផលប្រយោជន៍ដល់សង្គមជាតិគ្រប់ជំនាន់។

**មាត្រា៣ ._**

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំនិងគ្រប់គ្រងតំបន់ការពារទេសភាពបឹងយ៉ាកអោមយ៉ាកកាវ៉ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលខេត្តរតនគិរី និងកងកម្លាំងប្រដាប់អាវុធមានសមត្ថកិច្ចដើម្បីធានាកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាពស្របតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន។

**មាត្រា៤ ._**

ព្រំប្រទល់និងផ្ទៃក្រឡាតំបន់ការពារទេសភាពបឹងយ៉ាកអោម យ៉ាកកាវ៉ នឹងត្រូវធ្វើបច្ចុប្បន្នភាពនិងកែសម្រួលតាមរយៈការសិក្សាស្រាវជ្រាវនិងប្រមូលទិន្នន័យ ដោយផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រ ដើម្បីធានាតម្លៃនិងផលប្រយោជន៍ធនធានជីវៈចម្រុះ សេដ្ឋកិច្ច សង្គម និងវប្បធម៌។ ៸

**មាត្រា៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ៥ កើត ខែ [illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# តំបន់ការពារទេសភាពបឹងយ៉ាកឡោម យ៉ាកកាវ៉

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៤៦ អនក្រ.បក ភូមិសាស្ត្រ ឃុំសេដា ស្រុកលំផាត់ ខេត្តរតនគិរី ផ្ទៃដី ទំហំ ១៣២,៥០ ហិកតា

ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០២០







| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 730779 | 1499059 | 21 | 730772 | 1498533 |
| 2 | 730753 | 1499160 | 22 | 730645 | 1498504 |
| 3 | 730796 | 1499197 | 23 | 730524 | 1498448 |
| 4 | 730731 | 1499354 | 24 | 730708 | 1498338 |
| 5 | 730553 | 1499272 | 25 | 730723 | 1498412 |
| 6 | 730532 | 1499343 | 26 | 730877 | 1498465 |
| 7 | 730402 | 1499375 | 27 | 730985 | 1498515 |
| 8 | 730422 | 1499461 | 28 | 731120 | 1498596 |
| 9 | 730486 | 1499433 | 29 | 731251 | 1498613 |
| 10 | 730462 | 1499501 | 30 | 731357 | 1498727 |
| 11 | 730420 | 1499768 | 31 | 731436 | 1498844 |
| 12 | 730509 | 1499879 | 32 | 731516 | 1498933 |
| 13 | 730591 | 1499862 | 33 | 731638 | 1498903 |
| 14 | 730688 | 1499763 | 34 | 731694 | 1498974 |
| 15 | 730808 | 1499856 | 35 | 731645 | 1499071 |
| 16 | 730912 | 1499859 | 36 | 731728 | 1499259 |
| 17 | 730980 | 1500021 | 37 | 731779 | 1499407 |
| 18 | 730846 | 1498981 | 38 | 731592 | 1499622 |
| 19 | 730767 | 1498921 | 39 | 731459 | 1499928 |
| 20 | 730765 | 1498717 | 40 | 731126 | 1500032 |

ចំណុចនិយាមកា

ព្រំប្រទល់បឹងយ៉ាកឡោម យ៉ាកកាវ៉

0 200 400 Meters